**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តសៀមរាប**
លេខ: ០២១/២៣ ស.ស.រ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារដឹកនាំសម្របសម្រួលវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ខេត្តសៀមរាប

## អភិបាលនៃគណៈអភិបាលខេត្ត

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៩/៨៦៦ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ ស្តីពីការបង្កើតក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/នកម/០១១៩/០០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២២/១៤២១ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២២ ស្តីពីការតែងតាំងមុខតំណែងអភិបាល នៃគណៈអភិបាលខេត្តសៀមរាប
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- យោងសេចក្តីសម្រេចលេខ ០៥៤/២២ សសរ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២២ ស្តីពីការបង្កើតក្រុមការងារដឹកនាំសម្របសម្រួលវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភខេត្តសៀមរាប របស់រដ្ឋបាលខេត្តសៀមរាប
- យោងតាមការចាំបាច់របស់រដ្ឋបាលខេត្តសៀមរាប។



សាលាខេត្តសៀមរាប ផ្លូវ៦០ម៉ែត្រ ភូមិបឹងដូនប៉ា សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប Siem Reap Provincial Hall, 60m Street, Boeng Donpa Village, Sangkat Slorkram, Siem Reap Municipality, Siem Reap Province, E-mail: srphall@yahoo.com Tel: (855) 63 765-276, (855) 63 765 319, Fax: (855) 63 765 343

## សម្រេច

**ប្រការ១..**

ត្រូវបានបង្កើតក្រុមការងារដឹកនាំសម្របសម្រួលវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ខេត្តសៀមរាប ហៅកាត់ "ក.ដ.ស.ស.អ" ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ទៀ សីហា** | អភិបាល នៃគណៈអភិបាលខេត្ត | ប្រធាន |
| ២-លោក | **អ៊ឹង គឹមលាង** | អភិបាលរង នៃគណៈអភិបាលខេត្ត | អនុប្រធាន |
| ៣-លោក | **លី វណ្ណៈ** | នាយករដ្ឋបាលសាលាខេត្ត | អនុប្រធាន |
| ៤-លោកស្រី | **ឃី នារីរ័ត្ន** | ប្រធានសម្របសម្រួលដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល | សមាជិក |
| ៥-លោក | **ចឹក គឹមដុន** | នាយករងរដ្ឋបាលសាលាខេត្ត | សមាជិក |
| ៦-លោក | **លី ប៊ុនណា** | ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត | សមាជិក |
| ៧-លោក | **ឆា គឹមសុទ្ធ** | ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត | សមាជិក |
| ៨-លោក | **ទូច ម៉ាឡា** | ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត | សមាជិក |
| ៩-លោក | **ហាក់ សុធារ៉ា** | ប្រធានមន្ទីរផែនការខេត្ត | សមាជិក |
| ១០-លោក | **ជា ឧុធឡុង** | ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ខេត្ត | សមាជិក |
| ១១-លោក | **តឿន គឹមលី** | ប្រធានមន្ទីរពាណិជ្ជកម្មខេត្ត | សមាជិក |
| ១២-លោក | **លឹម សុខុន** | ប្រធានមន្ទីរព័ត៌មានខេត្ត | សមាជិក |
| ១៣-លោក | **ច័ន្ទ សុខុមចិត្តា** | ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត | សមាជិក |
| ១៤-លោកស្រី | **គ្រាច់ ស៊ីថាវី** | ប្រធានមន្ទីរកិច្ចការនារីខេត្ត | សមាជិកា |
| ១៥-លោក | **គង់ សំអឿន** | ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត | សមាជិក |
| ១៦-លោកឧកញ៉ាបណ្ឌិត | **ហ៊ុយ គៀវ** | ប្រធានសភាពាណិជ្ជកម្មមណ្ឌលខេត្តសៀមរាប-ឧត្តរមានជ័យ | សមាជិក |
| ១៧-លោក | **អ៊ឹង សុភ័ណ** | នាយកទីចាត់ការអន្តរវិស័យសាលាខេត្ត | សមាជិក |
| ១៨-លោក | **សោម សមសក្តិ** | នាយកទីចាត់ការហិរញ្ញវត្ថុសាលាខេត្ត | សមាជិក |
| ១៩-លោក | **ធិព្វ ពិសិទ្ធ** | នាយកទីចាត់ការផែនការ និងវិនិយោគសាលាខេត្ត | សមាជិក |
| ២០-លោក | **គុប ធឿន** | អនុប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ខេត្ត | សមាជិក |
| ២១-លោក | **មាស សឿម** | អនុប្រធានមន្ទីរពាណិជ្ជកម្មខេត្ត | សមាជិក |
| ២២-លោក | **វន ម៉ូលីវ៉ាន** | អនុប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត | សមាជិក |
| ២៣-លោក | **ហៀវ ស៊ីថាត** | ប្រធានការិ.សេដ្ឋកិច្ច និងសង្គមកិច្ចសាលាខេត្ត | សមាជិក |
| ២៤-លោក | **មឿន សុគុណា** | ប្រធានការិ.សុខុមាលភាពកុមារ នៃមន្ទីរ ស.អ.យ ខេត្ត | សមាជិក |
| ២៥-លោកស្រី | **ណាន ម៉ៅ** | ប្រធានការិយាល័យនៃមន្ទីរកិច្ចការនារីខេត្ត | សមាជិកា |
| ២៦-លោកស្រី | **ឡុញ សុខឌួច** | ប្រធានការិ.អភិវឌ្ឍន៍សហគមន៍ នៃមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត | សមាជិកា |
| ២៧-លោក | **ពេជ្រ ប៉ុលកូណ៌** | អនុប្រធានការិ.សេដ្ឋកិច្ច និងសង្គមកិច្ចសាលាខេត្ត | សមាជិក |
| ២៨-លោក | **តាន់ ជាយុទ្ធថា** | អនុប្រធានការិយាល័យ នៃមន្ទីរ ម.ក.ខ ខេត្ត | សមាជិក |
| ២៩-លោកស្រី | **ញាណ ហេមា** | អនុប្រធានការិ.នៃមន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្ត | សមាជិកា |
| ៣០-លោកស្រី | **ធឿន សុភារី** | មន្ត្រីកម្មវិធីអាហារូបត្ថម្ភនៃមន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្ត | សមាជិកា |
| ៣១-លោកស្រី | **កង សុភី** | មន្ត្រីការិ.បឋមសិក្សានៃមន្ទីរអប់រំ យុវជន និងកីឡាខេត្ត | សមាជិកា |
| ៣២-លោក | **ឌិម ផល** | មន្ត្រីការិ.សេដ្ឋកិច្ច និងសង្គមកិច្ចសាលាខេត្ត | សមាជិក |

៣៣-លោក លោកស្រី តំណាងអង្គការសង្គមស៊ីវិលពាក់ព័ន្ធនឹងវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ.. សមាជិក

**ប្រការ២..**

ក្រុមការងារដឹកនាំសម្របសម្រួលវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ខេត្តសៀមរាប មានតួនាទីភារកិច្ចដូចខាងក្រោម៖

- ផ្តល់មតិយោបល់ដល់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ដើម្បីប្រើប្រាស់ជាធាតុចូលសម្រាប់រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ កម្មវិធី និងគម្រោងនានាដែលពាក់ព័ន្ធនឹងវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ
- សម្របសម្រួល និងជំរុញការអនុវត្តសកម្មភាពអាទិភាពដឹកនាំតាមវិស័យ អន្តរវិស័យ និងពហុវិស័យដូចមានចែងនៅក្នុងយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ លើកទី២ ឆ្នាំ ២០១៩-២០២៣ ឱ្យទទួលបានជោគជ័យ
- រៀបចំកិច្ចប្រជុំ វេទិកា ឬសិក្ខាសាលានានា ដែលពាក់ព័ន្ធនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ
- ចូលរួម និងដឹកនាំការសិក្សាស្រាវជ្រាវលើវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ
- ផ្សព្វផ្សាយតាមប្រព័ន្ធព័ត៌មានគ្រប់រូបភាព ឱ្យបានទូលំទូលាយដើម្បីលើកកម្ពស់វិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ
- ដឹកនាំសម្របសម្រួលបណ្តាអង្គការដៃគូអភិវឌ្ឍន៍នានា ដែលធ្វើការងារលើវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដើម្បីលើកកម្ពស់វិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ
- ដឹកនាំសម្របសម្រួល តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលអនុវត្តគម្រោងនានា ដែលពាក់ព័ន្ធនឹងវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ
- ដឹកនាំសម្របសម្រួលការងារកសាងផែនការសកម្មភាពអន្តរវិស័យ ឬពហុវិស័យរបស់អង្គការដៃគូអភិវឌ្ឍន៍នានា ដែលធ្វើការលើវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ
- រៀបចំរបាយការណ៍វឌ្ឍនភាពស្តីពីវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ ជូនក្រុមប្រឹក្សាស្តារអភិឌ្ឍន៍វិស័យកសិកម្ម និងជនបទ
- សហការឱ្យបានជិតស្និទ្ធជាមួយនឹងវិស័យឯកជន គ្រឹះស្ថានសិក្សា និងក្រុមយុវជន ដើម្បីលើកកម្ពស់វិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ
- កៀរគរធនធានមនុស្ស និងថវិកាពីប្រភពផ្សេងៗ ដើម្បីជំរុញការអភិឌ្ឍវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ឱ្យកាន់តែល្អប្រសើរ។

**ប្រការ៣..**

ប្រធានក្រុមការងារដឹកនាំសម្របសម្រួលសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ខេត្តសៀមរាប មានតួនាទីភារកិច្ចដូចខាងក្រោម៖

- ដឹកនាំសម្របសម្រួលការងារនានាលើវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ដឹកនាំរាល់កិច្ចប្រជុំរបស់ ក.ជ.ស.ស.អ ទៅតាមរបៀបវារៈនៃកិច្ចប្រជុំ និងផ្តល់យោបល់គ្រប់គ្រាន់សម្រាប់ការសិក្សាលើប្រធានបទនីមួយៗដែលទាក់ទងនឹងវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ
- ប្រធាន ក.ជ.ស.ស.អ មានសិទ្ធិផ្ទេរសិទ្ធិជូនអនុប្រធានដើម្បីដឹកនាំសម្របសម្រួលក្រុមការងារនេះ
- ធានាប្រក្រតីភាពនៃដំណើរការ ក.ជ.ស.ស.អ ឱ្យមានប្រសិទ្ធភាព គណនេយ្យភាព និងនិរន្តរភាព

- ផ្តល់ការគាំទ្រ និងលើកទឹកចិត្តគ្រប់រូបភាពដល់សមាជិក ក.ដ.ស.ស.អ ដើម្បីបង្កើនប្រសិទ្ធភាព គណនេយ្យភាព តម្លាភាព ក្នុងការអនុវត្តផែនការលើកកម្ពស់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ តាមដែនសមត្ថកិច្ចរៀងៗខ្លួន
- ជួយសម្របសម្រួលការអនុវត្តគម្រោងសន្តិសុខស្បៀង និងអាហារូបត្ថម្ភដែលអនុវត្តដោយសម្ព័ន្ធអង្គការសង្គមស៊ីវិលដើម្បីអាហារូបត្ថម្ភកម្ពុជា និងដៃគូអភិវឌ្ឍន៍នានា។

**ប្រការ៤..**

ប្រធានសម្របសម្រួលដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល គឺជាប្រធានប្តូរវេនរៀងរាល់មួយ (០១) ឆ្នាំម្តង តាមរយៈការជ្រើសរើសតាំងពីប្រធាន ក.ដ.ស.ស.អ ឬតាមរយៈការសម្របសម្រួល និងមានការកិច្ចជួយសម្របសម្រួល ក.ដ.ស.ស.អ ជាមួយនឹងសម្ព័ន្ធអង្គការសង្គមស៊ីវិលដើម្បីអាហារូបត្ថម្ភកម្ពុជា និងអង្គការដៃគូអភិវឌ្ឍន៍នានា ដែលកំពុងបម្រើការងារនៅក្នុងខេត្តឱ្យចូលរួមក្នុង ក.ដ.ស.ស.អ។

**ប្រការ៥..**

ត្រូវបានបង្កើតក្រុមលេខាធិការដ្ឋានមួយជាជំនួយការ ឱ្យក្រុមការងារដឹកនាំសម្របសម្រួលវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភខេត្ត ដែលមានសមាសភាពដូចខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១-លោក | **លី ទណ្ណា:** | នាយករដ្ឋបាលសាលាខេត្ត | ប្រធាន |
| ២-លោក | **ចឹក គឹមដុន** | នាយករងរដ្ឋបាលសាលាខេត្ត | អនុប្រធាន |
| ៣-លោក | **អ៊ឹម សុភ័ណា** | នាយកទីចាត់ការអន្តរវិស័យសាលាខេត្ត | សមាជិក |
| ៤-លោក | **ឌិញ ពិសិទ្ធ** | នាយកទីចាត់ការផែនការ និងវិនិយោគសាលាខេត្ត | សមាជិក |
| ៥-លោក | **ហ៊ុំ ចាយ** | នាយករងទីចាត់ការអន្តរវិស័យសាលាខេត្ត | សមាជិក |
| ៦-លោក | **សេង ទិសាល** | ប្រធានការិ.នៃទីចាត់ការផែនការ និងវិនិយោគសាលាខេត្ត | សមាជិក |
| ៧-លោកស្រី | **ម៉ក់ សុទិបុល** | ប្រធានការិយាល័យហិរញ្ញកិច្ចសាលាខេត្ត | សមាជិក |
| ៨-លោក | **លី រតន:** | ប្រធានការិយាល័យគណនេយ្យសាលាខេត្ត | សមាជិក |
| ៩-លោក | **ពេជ្រ ប៉ុលត្ថណ៍** | អនុប្រធានការិ.សេដ្ឋកិច្ច និងសង្គមកិច្ចសាលាខេត្ត | សមាជិក |
| ១០-លោកស្រី | **ឈន សុគន្ធា** | អនុប្រធានការិ.របៀប និងឯកសារសាលាខេត្ត | សមាជិកា |
| ១១-លោក | **ជិម ផល** | មន្ត្រីការិ.សេដ្ឋកិច្ច និងសង្គមកិច្ចសាលាខេត្ត | សមាជិក |

**ប្រការ៦..**

លេខាធិការដ្ឋាននៃ ក.ដ.ស.ស.អ មានភារកិច្ចដូចខាងក្រោម៖
- រៀបចំរបៀបវារៈប្រជុំដាក់ឆ្លងប្រធាន ក.ដ.ស.ស.អ ដើម្បីពិនិត្យ និងសម្រេច
- រៀបចំលិខិតអញ្ជើញសមាជិកចូលរួមប្រជុំ និងចាត់ចែងបញ្ជូនលិខិតអញ្ជើញ និងរបៀបវារៈជូនសមាជិកអង្គប្រជុំ
- កត់ត្រាកំណត់ហេតុនៃអង្គប្រជុំនីមួយៗ
- រៀបចំរបាយការណ៍វឌ្ឍនភាពរបស់ ក.ដ.ស.ស.អ ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ ដើម្បីដាក់ជូនប្រធាន ក.ដ.ស.ស.អ ពិនិត្យ និងដាក់ឆ្លងកិច្ចប្រជុំរបស់ ក.ដ.ស.ស.អ
- ចាត់ចែងរៀបចំការងាររដ្ឋបាលនានាតាមការកំណត់
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធាន ក.ដ.ស.ស.អ ប្រគល់ជូន។

**ប្រការ៧..**

ក.ដ.ស.ស.អ មានសិទ្ធិបង្កើតអនុប្រធានក្រុមការងារជំនាញបច្ចេកទេស និងអាចប្រើប្រាស់មន្ត្រីអង្គភាពសាមី ដើម្បីចូលរួមអនុវត្តភារកិច្ចរបស់ក្រុមការងារដឹកនាំសម្របសម្រួលវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។

**ប្រការ៨.-**

ក.ជ.ស.ស.អ ត្រូវធ្វើការប្រជុំសាមញ្ញ ៣ (បី)ខែម្តង។ ក្នុងករណីចាំបាច់ប្រធាន ក.ជ.ស.ស.អ អាចកោះប្រជុំជាវិសាមញ្ញបាន។

សមាជិក ក.ជ.ស.ស.អ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ក.ជ.ស.ស.អ។ ក្នុងករណីមានធុរៈប្រធាន ក.ជ.ស.ស.អ អាចផ្ទេរសិទ្ធិជូនអនុប្រធានដើម្បីដឹកនាំការប្រជុំ។

ប្រធាន ក.ជ.ស.ស.អ មានសិទ្ធិអញ្ជើញតំណាងមន្ទីរ អង្គភាព អ្នកឯកទេស ដៃលពាក់ព័ន្ធអង្គការដៃគូអភិវឌ្ឍន៍នានា និងវិស័យឯកជន ចូលរួមប្រជុំពិភាក្សា និងផ្តល់យោបល់ក្នុងអង្គប្រជុំតាមការចាំបាច់។

**ប្រការ៩.-**

ក.ជ.ស.ស.អ មានសិទ្ធិប្រើប្រាស់ត្រារបស់រដ្ឋបាលខេត្ត ជាផ្លូវការ។ ក.ជ.ស.ស.អ មានសិទ្ធិប្រើប្រាស់មន្ត្រីរាជការក្រោមឱវាទតាមការចាំបាច់។

**ប្រការ១០.-**

ថវិកាសម្រាប់ដំណើរការលេខាធិការដ្ឋាននៃ ក.ជ.ស.ស.អ ត្រូវប្រើប្រាស់ថវិការដ្ឋបាលខេត្ត និងមន្ទីរពាក់ព័ន្ធ និងកៀរគរពីដៃគូអភិវឌ្ឍន៍នានា និងសម្ព័ន្ធអង្គការស៊ីវិលដើម្បីអាហារូបត្ថម្ភនៅកម្ពុជា។

**ប្រការ១១.-**

សេចក្តីសម្រេចលេខ ០៥៤/២២ សសរ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២២ របស់រដ្ឋបាលខេត្តសៀមរាប ស្តីពីការបង្កើតក្រុមការងារដឹកនាំសម្របសម្រួលវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភខេត្តសៀមរាប ត្រូវទុកជានិរាករណ៍។

**ប្រការ១២.-**

នាយករដ្ឋបាលសាលាខេត្ត ប្រធានមន្ទីរ-អង្គភាពពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ និងប្រការ៥ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ១៥ កើត ខែ ចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

ធ្វើនៅខេត្តសៀមរាប ថ្ងៃទី ០៥ ខែមេសា ឆ្នាំ២០២៣

**អភិបាលខេត្ត**

**ទៀ សីហា**

**កន្លែងទទួល៖**

-ក្រសួងមហាផ្ទៃ

-ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ

-ក្រុមប្រឹក្សាខេត្ត

-ដូចប្រការ១២

-ឯកសារ កាលប្បវត្តិ